ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៧៥ សហវ.អ.ល.ន

# សេចក្តីណែនាំ
## ស្តីពី
## កាតព្វកិច្ចបង់ពន្ធអាករចំពោះការផ្គត់ផ្គង់ទំនិញដោយមានថែមទំនិញ ឬផ្តល់ជារង្វាន់ របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសង្កេតឃើញថា ក្នុងរយៈពេលកន្លងមក សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក បាន និងកំពុងពង្រីកទីផ្សារដោយប្រើយុទ្ធសាស្ត្រជំរុញការលក់ក្រោមរូបភាពជាការផ្គត់ផ្គង់ទំនិញ ដោយមានថែមទំនិញរបស់សហគ្រាសឬទំនិញដទៃ ឬផ្តល់ជារង្វាន់តាមរយៈក្រវិលកំប៉ុង គម្របដប ឬវិធីផ្សេងទៀតផ្តល់ជូនអតិថិជនរបស់ខ្លួន។ ដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ និងក្នុងគោលបំណងពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុកអំពីកាតព្វកិច្ចបង់ពន្ធអាករ ចំពោះការផ្គត់ផ្គង់ទំនិញដោយមានថែមទំនិញ ឬផ្តល់ជារង្វាន់ផ្សេងៗ ដូចខាងក្រោម៖

### ១- ការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញជាស្តុកសម្រាប់លក់

ការផ្គត់ផ្គង់ទំនិញដោយមានថែមទំនិញឬផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់ ត្រូវចាត់ទុកជាការផ្គត់ផ្គង់ជាប់អាករ ដែលសហគ្រាសត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

ក- ចំពោះសហគ្រាសផលិតក្នុងស្រុកនូវទំនិញជាប់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ៖

- ត្រូវជាប់អាករពិសេស និងអាករសម្រាប់បំភ្លឺសាធារណៈ ចំពោះការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញផលិតក្នុងស្រុកដែលជាប់អាករពិសេសផង និងអាករសម្រាប់បំភ្លឺសាធារណៈផង។ ក្នុងករណីទំនិញផលិតក្នុងស្រុកមិនជាប់អាករសម្រាប់បំភ្លឺសាធារណៈ នោះសហគ្រាសត្រូវបង់តែអាករពិសេសប៉ុណ្ណោះ។ មូលដ្ឋានគិតអាករត្រូវផ្អែកតាមតម្លៃទីផ្សារនៃការផ្គត់ផ្គង់ទំនិញជាប់អាករនោះ
- ត្រូវជាប់អាករសម្រាប់បំភ្លឺសាធារណៈ ក្នុងករណីការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញជាប់អាករសម្រាប់បំភ្លឺសាធារណៈ ដែលសហគ្រាសបាននាំចូលដោយផ្ទាល់
- ត្រូវជាប់អាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដោយអនុញ្ញាតឱ្យយកមូលដ្ឋានគិតអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ស្មើនឹងថ្លៃដើមនៃទំនិញជាប់អាករនោះ
- ត្រូវជាប់ពន្ធលើប្រាក់ចំណូល ដោយអនុញ្ញាតឱ្យទទួលស្គាល់ចំណូលស្មើនឹងចំណាយថ្លៃដើម។

ខ- ចំពោះសហគ្រាសនាំចូលទំនិញជាប់អាករសម្រាប់បំភ្លឺសាធារណៈ៖

- ត្រូវជាប់អាករសម្រាប់បំភ្លឺសាធារណៈ ដោយមូលដ្ឋានគិតអាករត្រូវផ្អែកតាមតម្លៃទីផ្សារនៃការផ្គត់ផ្គង់ទំនិញជាប់អាករនោះ
- ត្រូវជាប់អាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដោយអនុញ្ញាតឱ្យយកមូលដ្ឋានគិតអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ស្មើនឹងថ្លៃដើមនៃការនាំចូលទំនិញជាប់អាករនោះ
- ត្រូវជាប់ពន្ធលើប្រាក់ចំណូល ដោយអនុញ្ញាតឱ្យទទួលស្គាល់ចំណូលស្មើនឹងចំណាយថ្លៃដើម។

គ- ចំពោះសហគ្រាសផ្គត់ផ្គង់ទំនិញដែលមិនជាប់អាករពិសេស និងអាករសម្រាប់បំភ្លឺសាធារណៈ៖

- ត្រូវជាប់អាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដោយអនុញ្ញាតឱ្យយកមូលដ្ឋានគិតអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ស្មើនឹងថ្លៃដើមនៃទំនិញជាប់អាករនោះ
- ត្រូវជាប់ពន្ធលើប្រាក់ចំណូល ដោយអនុញ្ញាតឱ្យទទួលស្គាល់ចំណូលស្មើនឹងចំណាយថ្លៃដើម។

**២- ការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញដែលមិនមែនជាស្តុកសម្រាប់លក់ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ**

ការផ្គត់ផ្គង់ទំនិញដោយមានថែមឬផ្តល់រង្វាន់នូវទំនិញដែលមិនមែនជាស្តុកសម្រាប់លក់ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ សហគ្រាសត្រូវអនុវត្តដូចខាងក្រោម៖

ក- មិនត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ដែលជាកម្មវត្ថុនៃអាករលើតម្លៃបន្ថែម ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលឡើយ។

ខ- អាករលើតម្លៃបន្ថែមដែលសហគ្រាសបានបង់លើការទិញទំនិញយកមកប្រើប្រាស់សម្រាប់ការលក់ដោយមានថែមទំនិញឬផ្តល់ជារង្វាន់ មិនត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលឡើយ ប៉ុន្តែត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

**៣- ការអនុញ្ញាតជាចំណាយ**

ចំពោះការថែមទំនិញឬផ្តល់ជារង្វាន់ផ្សេងៗដល់អតិថិជនរបស់ខ្លួនដើម្បីជំរុញការលក់ដូចមានចែងក្នុងចំណុចទី១ និងចំណុចទី២ ខាងលើ សហគ្រាសត្រូវអនុវត្តដូចខាងក្រោម៖

ក- ត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

ខ- ត្រូវកត់ត្រាឱ្យច្បាស់លាស់ក្នុងបញ្ជីគណនេយ្យ និងត្រូវមានសក្ខីបត្រគាំទ្រ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល ព្រមទាំងរក្សាទុកឯកសារក្នុងរយៈពេល ១០ឆ្នាំ សម្រាប់គោលដៅពន្ធដារ។

**៤- កាតព្វកិច្ចដទៃទៀតរបស់សហគ្រាស**

ក- ការថែមទំនិញឬផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់ និងទំនិញដែលមិនមែនជាស្តុកសម្រាប់លក់ ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ សហគ្រាសត្រូវបំពេញលក្ខខណ្ឌទាំងបីដូចខាងក្រោម៖

- ត្រូវមានគោលការណ៍និងឯកសារផ្ទៃក្នុងច្បាស់លាស់អំពីការពង្រីកទីផ្សារ ដែលមានការសម្រេចពីថ្នាក់ដឹកនាំរបស់សហគ្រាស ដោយមានបញ្ជាក់អំពីលក្ខខណ្ឌនៃការលក់ដោយមានថែមទំនិញ (បរិមាណ តម្លៃ លក្ខខណ្ឌនៃការលក់ទំនិញដែលត្រូវថែម) ឬផ្តល់រង្វាន់នូវទំនិញ និងរយៈពេលនៃការពង្រីកទីផ្សារ
- ត្រូវអនុវត្តជាទូទៅចំពោះអតិថិជន ស្របតាមគោលការណ៍និងលក្ខខណ្ឌនៃការលក់ដោយមានថែមទំនិញឬផ្តល់រង្វាន់នូវទំនិញឬរង្វាន់ផ្សេងៗក្រៅពីទំនិញ
- ត្រូវមានការផ្សព្វផ្សាយជាសាធារណៈ។

ខ- សម្រាប់គោលដៅនៃការប្រកាសបង់ពន្ធអាករប្រចាំខែ សហគ្រាសត្រូវរៀបចំបណ្ណលក់សម្រាប់ប្រកាសពន្ធ (Tax Sale Voucher) សរុបប្រចាំខែ ដោយបូកសរុបតម្លៃនៃទំនិញដែលបានថែមឬផ្តល់រង្វាន់ជាទំនិញជាប់អាករឬរង្វាន់ផ្សេងៗក្រៅពីទំនិញ ដើម្បីប្រកាសបង់ពន្ធអាករនៅក្នុងប្រព័ន្ធប្រកាសពន្ធអាជីវកម្មប្រចាំខែតាមអនឡាញ (e-Filing)។ ទម្រង់បណ្ណលក់សម្រាប់ប្រកាសពន្ធសរុបប្រចាំខែ ត្រូវមានកាលបរិច្ឆេទ លេខរៀងជាលំដាប់ពេញមួយឆ្នាំ និងព័ត៌មានដូចគំរូក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ ដោយត្រូវបំពេញព័ត៌មានតាមប្រភេទអាជីវកម្មដូចខាងក្រោម៖

- សហគ្រាសផលិតក្នុងស្រុកនូវទំនិញជាប់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបំពេញព័ត៌មាននៅក្នុងទម្រង់បណ្ណលក់ទី១
- សហគ្រាសនាំចូលនូវទំនិញជាប់អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបំពេញព័ត៌មាននៅក្នុងទម្រង់បណ្ណលក់ទី២

- សហគ្រាសផលិតឬនាំចូលឬផ្គត់ផ្គង់ទំនិញទូទៅ (មិនជាប់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ) ត្រូវបំពេញព័ត៌មាននៅក្នុងទម្រង់បណ្ណលក់ទី៣
- សហគ្រាសផលិតក្នុងស្រុកនូវទំនិញជាប់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ និងសហគ្រាសនាំចូលនូវទំនិញជាប់អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបំពេញព័ត៌មាននៅក្នុងទម្រង់បណ្ណលក់នីមួយៗទៅតាមប្រភេទអាជីវកម្មដាច់ដោយឡែកពីគ្នា។

ឧទាហរណ៍នៃការផ្គត់ផ្គង់ទំនិញដោយមានថៃមទំនិញឬផ្តល់ជារង្វាន់ របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក មានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់ម្ចាស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុកដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

## ឧបសម្ព័ន្ធនៃសេចក្តីណែនាំលេខ ០៤៩ សហវ.អពដ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៤ ស្តីពីកាតព្វកិច្ចបង់ពន្ធអាករចំពោះការផ្គត់ផ្គង់ទំនិញដោយមានថែមទំនិញឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំបន្ថែមអំពីរបៀបកំណត់មូលដ្ឋានគិតពន្ធអាករ និងការគណនាពន្ធអាករចំពោះការថែមទំនិញឬផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់ និងទំនិញមិនមែនជាស្តុកសម្រាប់លក់ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ ដូចមានបញ្ជាក់ជាឧទាហរណ៍ខាងក្រោម៖

**១- ការលក់ថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញជាស្តុកសម្រាប់លក់**

**ក- ចំពោះសហគ្រាសផលិតក្នុងស្រុកនូវទំនិញជាប់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ៖**

**ឧទាហរណ៍ទី១៖**

សហគ្រាស ក ជាសហគ្រាសផលិតស្រាបៀរ និងកេសជ្ជៈគ្មានជាតិសុរា។ សហគ្រាសមានកម្មវិធីជំរុញការលក់រាល់អតិថិជនទិញស្រាបៀរចំនួន ២០កេស នឹងមានថែមស្រាបៀរចំនួន ២កេស និងទិញទឹកក្រូចចំនួន ២០កេស ថែមទឹកក្រូច ៥កេស ដែលមានរយៈពេល ៣ខែ គិតចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤។ នៅខែវិច្ឆិកា ឆ្នាំ២០២៤ សម្រាប់ការធ្វើកម្មវិធីជំរុញការលក់នេះ សហគ្រាសបានលក់ទំនិញ និងថែមទំនិញ ដែលមានព័ត៌មានដូចខាងក្រោម៖

(គិតជាដុល្លារអាមេរិក)

| ល.រ | ទំនិញ | បរិយាយ | បរិមាណ (កេស) | ថ្លៃលក់ /ឯកតា (មុនគិតអាករគ្រប់ប្រភេទ) | ថ្លៃដើម /ឯកតា |
|---|---|---|---|---|---|
| ១ | ស្រាបៀរ | លក់ | ៥០ ០០០ | ១០ | ៥ |
| | | ថែម | ៥ ០០០ | | |
| ២ | ទឹកក្រូច | លក់ | ២០ ០០០ | ៥ | ២ |
| | | ថែម | ៥ ០០០ | | |

**ការគណនាពន្ធអាករចំពោះទំនិញលក់ និងទំនិញថែម សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២៤ ដូចខាងក្រោម៖**

- គណនាអាករពិសេស៖

- តម្លៃគិតអាករលើស្រាបៀរ (លក់) = ៥០ ០០០កេស x ១០ដុល្លារអាមេរិក(ថ្លៃលក់)
= ៥០០ ០០០ដុល្លារអាមេរិក

**អាករពិសេសលើស្រាបៀរ** (លក់) = (៩០% x ៥០០ ០០០ដុល្លារអាមេរិក) x អត្រា៣០%
= **១៣៥ ០០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើស្រាបៀរ (ថែម) = ៥ ០០០កេស x ១០ដុល្លារអាមេរិក(ថ្លៃលក់)
= ៥០ ០០០ដុល្លារអាមេរិក

**អាករពិសេសលើស្រាបៀរ** (ថែម) = (៩០% x ៥០ ០០០ដុល្លារអាមេរិក) x អត្រា៣០%
= **១៣ ៥០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើទឹកក្រូច (លក់) = ២០ ០០០កេស x ៥ដុល្លារអាមេរិក(ថ្លៃលក់)
= ១០០ ០០០ដុល្លារអាមេរិក

**អាករពិសេសលើទឹកក្រូច** = (៩០% x ១០០ ០០០ដុល្លារអាមេរិក) x អត្រា១០%
= **៩ ០០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើទឹកក្រូច (ថែម) = ៥ ០០០កេស x ៥ដុល្លារអាមេរិក(ថ្លៃលក់)
= ២៥ ០០០ដុល្លារអាមេរិក

**អាករពិសេសលើទឹកក្រូច** (ថែម) = (៩០% x ២៥ ០០០ដុល្លារអាមេរិក) x អត្រា១០%
= **២ ២៥០ដុល្លារអាមេរិក**

- គណនាអាករសម្រាប់បំភ្លឺសាធារណៈ៖

| | |
|---|---|
| - តម្លៃគិតអាករលើស្រាបៀរ (លក់) | = ៥០០ ០០០ដុល្លារអាមេរិក + ១៣៥ ០០០ដុល្លារអាមេរិក (អាករពិសេស) |
| | = ៦៣៥ ០០០ដុល្លារអាមេរិក |
| **អាករសម្រាប់បំភ្លឺសាធារណៈ** | = ៦៣៥ ០០០ដុល្លារអាមេរិក x អត្រា៥% |
| | = **៣១ ៧៥០ដុល្លារអាមេរិក** |
| - តម្លៃគិតអាករលើស្រាបៀរ (ថែម) | = ៥០ ០០០ដុល្លារអាមេរិក + ១៣ ៥០០ដុល្លារអាមេរិក (អាករពិសេស) |
| | = ៦៣ ៥០០ដុល្លារអាមេរិក |
| **អាករសម្រាប់បំភ្លឺសាធារណៈ** | = ៦៣ ៥០០ដុល្លារអាមេរិក x អត្រា៥% |
| | = **៣ ១៧៥ដុល្លារអាមេរិក** |

- គណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖

| | |
|---|---|
| - តម្លៃគិតអាករលើស្រាបៀរ (លក់) | = ៥០០ ០០០ដុល្លារអាមេរិក + ១៣៥ ០០០ដុល្លារអាមេរិក (អាករពិសេស) + ៣១ ៧៥០ (អាករសម្រាប់បំភ្លឺសាធារណៈ) |
| | = ៦៦៦ ៧៥០ដុល្លារអាមេរិក |
| - តម្លៃគិតអាករលើស្រាបៀរ (ថែម) | = ៥ ០០០កេស x ៥ដុល្លារអាមេរិក (ថ្លៃដើម) |
| | = ២៥ ០០០ដុល្លារអាមេរិក |
| - តម្លៃគិតអាករលើទឹកក្រូច (លក់) | = ១០០ ០០០ ដុល្លារអាមេរិក + ៩ ០០០ដុល្លារអាមេរិក (អាករពិសេស) |
| | = ១០៩ ០០០ដុល្លារអាមេរិក |
| - តម្លៃគិតអាករលើទឹកក្រូច (ថែម) | = ៥ ០០០កេស x ២ដុល្លារអាមេរិក (ថ្លៃដើម) |
| | = ១០ ០០០ដុល្លារអាមេរិក |
| **តម្លៃគិតអាករសរុប** | = ៦៦៦ ៧៥០ដុល្លារអាមេរិក + ២៥ ០០០ដុល្លារអាមេរិក + ១០៩ ០០០ដុល្លារអាមេរិក + ១០ ០០០ដុល្លារអាមេរិក |
| | = **៨១០ ៧៥០ដុល្លារអាមេរិក** |
| **អាករលើតម្លៃបន្ថែម** | = ៨១០ ៧៥០ដុល្លារអាមេរិក x អត្រា១០% |
| | = **៨១ ០៧៥ដុល្លារអាមេរិក** |
| **ប្រាក់រំដោះពន្ធលើប្រាក់ចំណូល** | = ៨១០ ៧៥០ដុល្លារអាមេរិក x អត្រា១% |
| | = **៨ ១០៧.៥ដុល្លារអាមេរិក** |

**ឧទាហរណ៍ទី២៖**

សហគ្រាស ខ ជាសហគ្រាសផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា។ សហគ្រាសមានកម្មវិធីលក់ថែមទំនិញ និងផ្តល់ជារង្វាន់តាមរយៈក្រវិលកំប៉ុង រយៈពេល៣ខែ គិតចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤ ដោយរាល់ពេលអតិថិជនទិញស្រាបៀរចំនួន ១៥កេស នឹងមានថែមស្រាបៀរចំនួន ១កេស និងទិញទឹកក្រូចចំនួន២៥កេស ថែមទឹកក្រូច ៣កេស ព្រមទាំងអាចឈ្នះរង្វាន់តាមរយៈក្រវិលកំប៉ុង ដូចជាស្រាបៀរ រថយន្ត ម៉ូតូ មួក និងរង្វាន់ជាសាច់ប្រាក់។ នៅខែវិច្ឆិកា ឆ្នាំ២០២៤ សម្រាប់ការធ្វើកម្មវិធីជំរុញការលក់នេះ សហគ្រាសបានលក់ទំនិញ និងថែមទំនិញជាស្តុក និងបានផ្តល់ជូនអតិថិជនដែលបានឈ្នះរង្វាន់តាមរយៈក្រវិលកំប៉ុង ដែលមានព័ត៌មានដូចខាងក្រោម៖

- ការលក់ទំនិញ ការថែម និងផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់៖

( គិតជាដុល្លារអាមេរិក)

| ល.រ | ទំនិញ | បរិយាយ | បរិមាណ (កេស) | ថ្លៃលក់ /ឯកតា (មុនគិតអាករគ្រប់ប្រភេទ) | ថ្លៃដើម /ឯកតា |
|---|---|---|---|---|---|
| ១ | ស្រាបៀរ | លក់ | ៦០ ០០០ | ១០ | ៥ |
| | | ថែម | ៤ ០០០ | | |
| | | រង្វាន់ | ១ ០០០ | | |
| ២ | ទឹកក្រូច | លក់ | ២៥ ០០០ | ៥ | ២ |
| | | ថែម | ៣ ០០០ | | |

- ការផ្តល់រង្វាន់តាមរយៈគ្រវិលកំប៉ុងនូវទំនិញមិនមែនជាស្តុកសម្រាប់លក់ និងរង្វាន់ក្រៅពីទំនិញ៖

( គិតជាដុល្លារអាមេរិក)

| ល.រ | បរិយាយ | បរិមាណ | ថ្លៃដើមទិញចូល (រួមអាករ) /ឯកតា |
|---|---|---|---|
| ១ | រថយន្ត | ១ | ៥០ ០០០ |
| ២ | ម៉ូតូ | ៥ | ១ ៥០០ |
| ៣ | មួក | ១ ០០០ | ២ |
| ៤ | សាច់ប្រាក់ | ២ ០០០ | ១០ |

**ការគណនាពន្ធអាករចំពោះទំនិញលក់ និងទំនិញថែម សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២៤ ដូចខាងក្រោម៖**

- គណនាអាករពិសេស៖

- តម្លៃគិតអាករលើស្រាបៀរ (លក់) = ៦០ ០០០កេស x ១០ដុល្លារអាមេរិក (ថ្លៃលក់)
= ៦០០ ០០០ដុល្លារអាមេរិក

**អាករពិសេសលើស្រាបៀរ** (លក់) = (៩០% x ៦០០ ០០០ដុល្លារអាមេរិក) x អត្រា៣០%
= **១៦២ ០០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើស្រាបៀរ (ថែម) = ៤ ០០០កេស x ១០ដុល្លារអាមេរិក (ថ្លៃលក់)
= ៤០ ០០០ដុល្លារអាមេរិក

**អាករពិសេសលើស្រាបៀរ** (ថែម) = (៩០% x ៤០ ០០០ដុល្លារអាមេរិក) x អត្រា៣០%
= **១០ ៨០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើស្រាបៀរ (រង្វាន់) = ១ ០០០កេស x ១០ដុល្លារអាមេរិក (ថ្លៃលក់)
= ១០ ០០០ដុល្លារអាមេរិក

**អាករពិសេសលើស្រាបៀរ** (រង្វាន់) = (៩០% x ១០ ០០០ដុល្លារអាមេរិក) x អត្រា៣០%
= **២ ៧០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើទឹកក្រូច (លក់) = ២៥ ០០០កេស x ៥ដុល្លារអាមេរិក (ថ្លៃលក់)
= ១២៥ ០០០ដុល្លារអាមេរិក

**អាករពិសេសលើទឹកក្រូច** (លក់) = (៩០% x ១២៥ ០០០ដុល្លារអាមេរិក) x អត្រា១០%
= **១១ ២៥០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើទឹកក្រូច (ថែម) = ៣ ០០០កេស x ៥ដុល្លារអាមេរិក (ថ្លៃលក់)
= ១៥ ០០០ដុល្លារអាមេរិក

**អាករពិសេសលើទឹកក្រូច** (ថែម) = (៩០% x ១៥ ០០០ដុល្លារអាមេរិក) x អត្រា១០%
= **១ ៣៥០ដុល្លារអាមេរិក**

- គណនាអាករសម្រាប់បំភ្លឺសាធារណៈ៖

- តម្លៃគិតអាករលើស្រាបៀរ (លក់) = ៦០០ ០០០ដុល្លារអាមេរិក + ១៦២ ០០០ដុល្លារអាមេរិក (អាករពិសេស)
  = ៧៦២ ០០០ដុល្លារអាមេរិក

**អាករសម្រាប់បំភ្លឺសាធារណៈ (លក់)** = ៧៦២ ០០០ដុល្លារអាមេរិក x អត្រា៥%
  = **៣៨ ១០០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើស្រាបៀរ (ថែម) = ៤០ ០០០ដុល្លារអាមេរិក + ១០ ៨០០ដុល្លារអាមេរិក (អាករពិសេស)
  = ៥០ ៨០០ដុល្លារអាមេរិក

**អាករសម្រាប់បំភ្លឺសាធារណៈ (ថែម)** = ៥០ ៨០០ដុល្លារអាមេរិក x អត្រា៥%
  = **២ ៥៤០ដុល្លារអាមេរិក**

- តម្លៃគិតអាករលើស្រាបៀរ (រង្វាន់) = ១០ ០០០ដុល្លារអាមេរិក + ២ ៧០០ដុល្លារអាមេរិក (អាករពិសេស)
  = ១២ ៧០០ដុល្លារអាមេរិក

**អាករសម្រាប់បំភ្លឺសាធារណៈ (រង្វាន់)** = ១២ ៧០០ដុល្លារអាមេរិក x អត្រា៥%
  = **៦៣៥ដុល្លារអាមេរិក**

- គណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖

- តម្លៃគិតអាករលើស្រាបៀរ (លក់) = ៦០០ ០០០ដុល្លារអាមេរិក + ១៦២ ០០០ ដុល្លារអាមេរិក (អាករពិសេស) + ៣៨ ១០០ដុល្លារអាមេរិក (អាករសម្រាប់បំភ្លឺសាធារណៈ)
  = ៨០០ ១០០ដុល្លារអាមេរិក
- តម្លៃគិតអាករលើស្រាបៀរ (ថែម) = ៤ ០០០កេស x ៥ដុល្លារអាមេរិក (ថ្លៃដើម)
  = ២០ ០០០ដុល្លារអាមេរិក
- តម្លៃគិតអាករលើស្រាបៀរ (រង្វាន់) = ១ ០០០កេស x ៥ដុល្លារអាមេរិក (ថ្លៃដើម)
  = ៥ ០០០ដុល្លារអាមេរិក
- តម្លៃគិតអាករលើទឹកក្រូច (លក់) = ១២៥ ០០០ដុល្លារអាមេរិក + ១១ ២៥០ដុល្លារអាមេរិក (អាករពិសេស)
  = ១៣៦ ២៥០ដុល្លារអាមេរិក
- តម្លៃគិតអាករលើទឹកក្រូច (ថែម) = ៣ ០០០កេស x ២ដុល្លារអាមេរិក (ថ្លៃដើម)
  = ៦ ០០០ដុល្លារអាមេរិក

**តម្លៃគិតអាករសរុប** = ៨០០ ១០០ដុល្លារអាមេរិក + ២០ ០០០ដុល្លារអាមេរិក + ៥ ០០០ដុល្លារអាមេរិក + ១៣៦ ២៥០ដុល្លារអាមេរិក + ៦ ០០០ដុល្លារអាមេរិក
  = **៩៦៧ ៣៥០ដុល្លារអាមេរិក**

- អាករលើតម្លៃបន្ថែម = ៩៦៧ ៣៥០ដុល្លារអាមេរិក x អត្រា១០%
  = **៩៦ ៧៣៥ដុល្លារអាមេរិក**
- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល = ៩៦៧ ៣៥០ដុល្លារអាមេរិក x អត្រា១%
  = **៩ ៦៧៣.៥ដុល្លារអាមេរិក**

- គណនាចំណាយលើការផ្ដល់រង្វាន់ទំនិញមិនមែនជាស្តុកសម្រាប់លក់ និងរង្វាន់ក្រៅពីទំនិញ៖

| | | |
|---|---|---|
| - ចំណាយលើរង្វាន់ជារថយន្ត | = | ១គ្រឿង x ៥០ ០០០ដុល្លារអាមេរិក |
| | = | ៥០ ០០០ដុល្លារអាមេរិក |
| - ចំណាយលើរង្វាន់ជាម៉ូតូ | = | ៥គ្រឿង x ១ ៥០០ដុល្លារអាមេរិក |
| | = | ៧ ៥០០ដុល្លារអាមេរិក |
| - ចំណាយលើរង្វាន់ជាមួក | = | ១ ០០០មួក x ២ដុល្លារអាមេរិក |
| | = | ២ ០០០ដុល្លារអាមេរិក |
| - ចំណាយរង្វាន់ជាសាច់ប្រាក់ | = | ២ ០០០រង្វាន់ x ១០ដុល្លារអាមេរិក |
| | = | ២០ ០០០ដុល្លារអាមេរិក |
| **តម្លៃសរុប** | = | ៥០ ០០០ដុល្លារអាមេរិក + ៧ ៥០០ដុល្លារអាមេរិក + ២ ០០០ដុល្លារអាមេរិក + ២០ ០០០ដុល្លារអាមេរិក |
| | = | **៧៩ ៥០០ដុល្លារអាមេរិក** |

**សម្គាល់៖** ការផ្ដល់រង្វាន់ជារថយន្ត ម៉ូតូ មួក និងសាច់ប្រាក់ ដែលមិនមែនជាស្តុកទំនិញសម្រាប់លក់ និងរង្វាន់ក្រៅពីទំនិញរបស់សហគ្រាស មិនត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ទំនិញដែលជាកម្មវត្ថុនៃការជាប់ពន្ធអាករឡើយ និងត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

**ខ- ចំពោះសហគ្រាសនាំចូលទំនិញជាប់អាករសម្រាប់បំភ្លឺសាធារណៈ៖**

**ឧទាហរណ៍ទី៣៖**

សហគ្រាស គ ជាសហគ្រាសនាំចូលស្រា និងកេសជ្ជៈគ្មានជាតិសុរា។ សហគ្រាសមានកម្មវិធីជំរុញការលក់រយៈពេល ៣ខែ គិតចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤ ដោយរាល់ពេលអតិថិជនទិញស្រាចំនួន ២០កេស នឹងមានថែមស្រាចំនួន ១កេស សូដាចំនួន ៥កេស និងឆត្រចំនួន ៥ដើម។ នៅខែវិច្ឆិកា ឆ្នាំ២០២៤ សម្រាប់ការធ្វើកម្មវិធីជំរុញការលក់នេះ សហគ្រាសបានលក់ទំនិញ និងថែមទំនិញដែលមានព័ត៌មានដូចខាងក្រោម៖

- ការលក់ទំនិញ និងការថែមទំនិញជាស្តុកសម្រាប់លក់៖

(គិតជាដុល្លារអាមេរិក)

| ល.រ | ទំនិញ | បរិយាយ | បរិមាណ (កេស) | ថ្លៃលក់ /ឯកតា (មុនគិតអាករគ្រប់ប្រភេទ) | ថ្លៃដើម /ឯកតា |
|---|---|---|---|---|---|
| ១ | ស្រា | លក់ | ៦ ០០០ | ២៥០ | ១៥០ |
| | | ថែម | ៣០០ | | |
| ២ | សូដា | លក់ | ២០ ០០០ | ៧ | ៤ |
| | | ថែម | ១ ៥០០ | | |

- ការថែមទំនិញមិនមែនជាស្តុកសម្រាប់លក់៖

(គិតជាដុល្លារអាមេរិក)

| ល.រ | បរិយាយ | បរិមាណ (ដើម) | ថ្លៃដើមទិញចូល (រួមអាករ) /ឯកតា |
|---|---|---|---|
| ១ | ឆត្រ | ១ ៥០០ | ៥ |

**ការគណនាពន្ធអាករចំពោះទំនិញលក់ និងទំនិញថែម សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២៤ ដូចខាងក្រោម៖**

- គណនាអាករសម្រាប់បំភ្លឺសាធារណៈ៖

| | | |
|---|---|---|
| - តម្លៃគិតអាករលើស្រា (លក់) | = | ៦ ០០០កេស x ២៥០ដុល្លារអាមេរិក (ថ្លៃលក់) |
| | = | ១ ៥០០ ០០០ដុល្លារអាមេរិក |
| **អាករសម្រាប់បំភ្លឺសាធារណៈ (លក់)** | = | ១ ៥០០ ០០០ដុល្លារអាមេរិក x អត្រា៥% |
| | = | **៧៥ ០០០ដុល្លារអាមេរិក** |

- តម្លៃគិតអាករលើស្រា (ថែម) = ៣០០កេស x ២៥០ដុល្លារអាមេរិក (ថ្លៃលក់)
= ៧៥ ០០០ដុល្លារអាមេរិក

**អាករសម្រាប់បំភ្លឺសាធារណៈ (ថែម)** = ៧៥ ០០០ដុល្លារអាមេរិក x អត្រា៥%
= **៣ ៧៥០ដុល្លារអាមេរិក**

- គណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖

- តម្លៃគិតអាករលើស្រា (លក់) = ១ ៥០០ ០០០ដុល្លារអាមេរិក + ៧៥ ០០០ដុល្លារអាមេរិក
= ១ ៥៧៥ ០០០ដុល្លារអាមេរិក

- តម្លៃគិតអាករលើស្រា (ថែម) = ៣០០កេស x ១៥០ដុល្លារអាមេរិក (ថ្លៃដើម)
= ៤៥ ០០០ដុល្លារអាមេរិក

- តម្លៃគិតអាករលើសូដា (លក់) = ២០ ០០០កេស x ៧ដុល្លារអាមេរិក (ថ្លៃលក់)
= ១៤០ ០០០ដុល្លារអាមេរិក

- តម្លៃគិតអាករលើសូដា (ថែម) = ១ ៥០០កេស x ៤ដុល្លារអាមេរិក (ថ្លៃដើម)
= ៦ ០០០ដុល្លារអាមេរិក

**តម្លៃគិតអាករសរុប** = ១ ៥៧៥ ០០០ដុល្លារអាមេរិក + ៤៥ ០០០ដុល្លារអាមេរិក
+ ១៤០ ០០០ដុល្លារអាមេរិក + ៦ ០០០ដុល្លារអាមេរិក
= **១ ៧៦៦ ០០០ដុល្លារអាមេរិក**

**អាករលើតម្លៃបន្ថែម** = ១ ៧៦៦ ០០០ដុល្លារអាមេរិក x អត្រា១០%
= **១៧៦ ៦០០ដុល្លារអាមេរិក**

**ប្រាក់រំដោះពន្ធលើប្រាក់ចំណូល** = ១ ៧៦៦ ០០០ដុល្លារអាមេរិក x អត្រា១%
= **១៧ ៦៦០ដុល្លារអាមេរិក**

- គណនាចំណាយលើការថែមទំនិញមិនមែនជាស្តុកសម្រាប់លក់៖

- ចំណាយលើការថែមឆត្រ = ១ ៥០០ដើម x ៥ដុល្លារអាមេរិក
= **៧ ៥០០ដុល្លារអាមេរិក**

**សម្គាល់៖** ការថែមឆត្រដែលមិនមែនជាស្តុកទំនិញសម្រាប់លក់របស់សហគ្រាស មិនត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ដែលជាកម្មវត្ថុនៃការជាប់ពន្ធអាករឡើយ និងត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

**គ- ចំពោះសហគ្រាសផ្គត់ផ្គង់ទំនិញដែលមិនជាប់អាករពិសេស និងអាករសម្រាប់បំភ្លឺសាធារណៈ៖**

**ឧទាហរណ៍ទី៤៖**

សហគ្រាស ឃ ជាសហគ្រាសផ្គត់ផ្គង់បរិក្ខារអេឡិចត្រូនិក។ សហគ្រាសមានកម្មវិធីជំរុញការលក់រយៈពេល ៣ខែ គិតចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤ ដោយរាល់ពេលទិញម៉ាស៊ីនត្រជាក់ចំនួន ១គ្រឿង នឹងមានថែមកំសៀវអគ្គិសនីចំនួន ១គ្រឿង និងអាវយឺតចំនួន ១។ នៅខែវិច្ឆិកា ឆ្នាំ២០២៤ សម្រាប់ការធ្វើកម្មវិធីជំរុញការលក់នេះ សហគ្រាសបានលក់ទំនិញ និងថែមទំនិញដែលមានព័ត៌មានដូចខាងក្រោម៖

- ការលក់ទំនិញ និងការថែមទំនិញជាស្តុកសម្រាប់លក់៖

(គិតជាដុល្លារអាមេរិក)

| ល.រ | ទំនិញ | បរិយាយ | បរិមាណ (គ្រឿង) | ថ្លៃលក់ /ឯកតា (មុនគិតអាករគ្រប់ប្រភេទ) | ថ្លៃដើម /ឯកតា |
|---|---|---|---|---|---|
| ១ | ម៉ាស៊ីនត្រជាក់ | លក់ | ១ ០០០ | ៥០០ | ៣៣០ |
| ២ | កំសៀវអគ្គិសនី | លក់ | ៣ ០០០ | ៣០ | ២០ |
| | | ថែម | ១ ០០០ | | |

▪ ការថែមទំនិញមិនមែនជាស្តុកសម្រាប់លក់៖

(គិតជាដុល្លារអាមេរិក)

| ល.រ | បរិយាយ | បរិមាណ (អាវ) | ថ្លៃដើមទិញចូល (រួមអាករ) /ឯកតា |
|---|---|---|---|
| ១ | អាវយឺត | ១ ០០០ | ៥ |

**គណនាពន្ធអាករចំពោះទំនិញលក់ និងទំនិញថែម សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២៤ ដូចខាងក្រោម៖**

- គណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖

- តម្លៃគិតអាករលើម៉ាស៊ីនត្រជាក់ (លក់) = ១ ០០០គ្រឿង x ៥០០ដុល្លារអាមេរិក (ថ្លៃលក់)
= ៥០០ ០០០ដុល្លារអាមេរិក

- តម្លៃគិតអាករលើកំសៀវអគ្គិសនី(លក់) = ៣ ០០០គ្រឿង x ៣០ដុល្លារអាមេរិក (ថ្លៃលក់)
= ៩០ ០០០ដុល្លារអាមេរិក

- តម្លៃគិតអាករលើកំសៀវអគ្គិសនី (ថែម) = ១ ០០០គ្រឿង x ២០ដុល្លារអាមេរិក (ថ្លៃដើម)
= ២០ ០០០ដុល្លារអាមេរិក

**តម្លៃគិតអាករសរុប** = ៥០០ ០០០ដុល្លារអាមេរិក + ៩០ ០០០ដុល្លារអាមេរិក + ២០ ០០០ដុល្លារអាមេរិក
**= ៦១០ ០០០ដុល្លារអាមេរិក**

- អាករលើតម្លៃបន្ថែម = ៦១០ ០០០ដុល្លារអាមេរិក x អត្រា១០%
**= ៦១ ០០០ដុល្លារអាមេរិក**

- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល = ៦១០ ០០០ដុល្លារអាមេរិក x អត្រា១%
**= ៦ ១០០ដុល្លារអាមេរិក**

- គណនាចំណាយលើការថែមទំនិញមិនមែនជាស្តុកសម្រាប់លក់៖

- ចំណាយលើការថែមអាវយឺត = ១ ០០០អាវ x ៥ដុល្លារអាមេរិក
**= ៥ ០០០ដុល្លារអាមេរិក**

**សម្គាល់៖** ការថែមអាវយឺតដែលមិនមែនជាស្តុកទំនិញសម្រាប់លក់របស់សហគ្រាស មិនត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ដែលជាកម្មវត្ថុនៃការជាប់ពន្ធអាករឡើយ និងត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

**២- ការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញមិនមែនជាស្តុកសម្រាប់លក់ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ**

**ឧទាហរណ៍ទី៥៖**

សហគ្រាស **ង** ជាសហគ្រាសលក់រថយន្ត។ សហគ្រាសមានកម្មវិធីជំរុញការលក់រយៈពេល ៣ខែ គិតចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤ ដោយរាល់ពេលអតិថិជនទិញរថយន្តចំនួន ១គ្រឿង នឹងមានថែមម៉ូតូចំនួន ១គ្រឿង ព្រមទាំងទទួលបានបណ្ណសាំងមានតម្លៃ ១ ០០០ដុល្លារអាមេរិក ឬសំបុត្រដំណើរកម្សាន្តទៅក្រៅប្រទេសមានតម្លៃ ១ ០០០ដុល្លារអាមេរិក។ នៅខែវិច្ឆិកា ឆ្នាំ២០២៤ សម្រាប់ការធ្វើកម្មវិធីជំរុញការលក់នេះ សហគ្រាសបានលក់ទំនិញ និងថែមទំនិញមិនមែនជាស្តុកសម្រាប់លក់ និងរង្វាន់ក្រៅពីទំនិញ ដែលមានព័ត៌មានដូចខាងក្រោម៖

- ការលក់ទំនិញជាស្តុកសម្រាប់លក់៖

(គិតជាដុល្លារអាមេរិក)

| ល.រ | ទំនិញ | បរិយាយ | បរិមាណ (គ្រឿង) | ថ្លៃលក់ /ឯកតា (មុនគិតអាករគ្រប់ប្រភេទ) | ថ្លៃដើម /ឯកតា |
|---|---|---|---|---|---|
| ១ | រថយន្ត | លក់ | ១០០ | ៥០ ០០០ | ៤៥ ០០០ |

▪ ការថែមទំនិញមិនមែនជាស្តុកសម្រាប់លក់ និងវង្វាន់ក្រៅពីទំនិញ៖

(គិតជាដុល្លារអាមេរិក)

| ល.រ | បរិយាយ | បរិមាណ | ថ្លៃដើមទិញចូល (រួមអាករ) /ឯកតា |
|---|---|---|---|
| ១ | ម៉ូតូ | ១០០ | ១ ៥០០ |
| ២ | បណ្ណសាំង | ៥០ | ១ ០០០ |
| ៣ | សំបុត្រដំណើរកម្សាន្ត | ៥០ | ១ ០០០ |

**គណនាពន្ធអាករចំពោះទំនិញលក់ និងទំនិញថែម សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២៤ ដូចខាងក្រោម៖**

▪ គណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖

- តម្លៃគិតអាករលើរថយន្ត (លក់) = ១០០គ្រឿង x ៥០ ០០០ដុល្លារអាមេរិក
= ៥ ០០០ ០០០ ដុល្លារអាមេរិក
- អាករលើតម្លៃបន្ថែម = ៥ ០០០ ០០០ដុល្លារអាមេរិក x អត្រា១០%
= **៥០០ ០០០ដុល្លារអាមេរិក**
- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល = ៥ ០០០ ០០០ដុល្លារអាមេរិក x អត្រា១%
= **៥០ ០០០ដុល្លារអាមេរិក**

▪ គណនាចំណាយលើការថែមទំនិញមិនមែនជាស្តុកសម្រាប់លក់ និងវង្វាន់ក្រៅពីទំនិញ៖

- ចំណាយលើការថែមម៉ូតូ = ១០០គ្រឿង x ១ ៥០០ដុល្លារអាមេរិក
= ១៥០ ០០០ដុល្លារអាមេរិក
- ចំណាយលើការថែមបណ្ណសាំង = ៥០បណ្ណ x ១ ០០០ដុល្លារអាមេរិក
= ៥០ ០០០ដុល្លារអាមេរិក
- ចំណាយលើការថែមសំបុត្រដំណើរកម្សាន្ត = ៥០សំបុត្រ x ១ ០០០ដុល្លារអាមេរិក
= ៥០ ០០០ដុល្លារអាមេរិក

**តម្លៃសរុប** = ១៥០ ០០០ដុល្លារអាមេរិក + ៥០ ០០០ដុល្លារអាមេរិក
+ ៥០ ០០០ដុល្លារអាមេរិក
= **២៥០ ០០០ដុល្លារអាមេរិក**

**សម្គាល់៖** ការថែមម៉ូតូ បណ្ណសាំង និងសំបុត្រដំណើរកម្សាន្ត ដែលមិនមែនជាស្តុកទំនិញសម្រាប់លក់ និងវង្វាន់ក្រៅពីទំនិញរបស់សហគ្រាស មិនត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ដែលជាកម្មវត្ថុនៃការជាប់ពន្ធអាករឡើយ និងត្រូវបានអនុញ្ញាតជាចំណាយកាត់កងបានសម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

# ទម្រង់បណ្ណលក់ទី១

**ឈ្មោះក្រុមហ៊ុន** ៖ ( **ជាភាសាខ្មែរ** )
Company Name ៖ ( In English )
លេខអត្តសញ្ញាណកម្មសារពើពន្ធ ( VATTIN )៖ □□□□-□□□□□□□□□
អាសយដ្ឋាន/Address ៖
ទូរស័ព្ទលេខ/Telephone ៖

## បណ្ណលក់សម្រាប់ប្រកាសពន្ធ ( Tax Sale Voucher )

សហគ្រាសផលិតក្នុងស្រុក ( ទំនិញជាប់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ )
សម្រាប់ខែ.......... ឆ្នាំ២០២x

លេខរៀងបណ្ណ ៖
Voucher No ៖
កាលបរិច្ឆេទ ៖
Date ៖

ការថែមទំនិញឬផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់ និងមិនមែនជាស្តុកសម្រាប់លក់ ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ

| ល.រ | ប្រភេទទំនិញថែម ឬផ្តល់ជារង្វាន់ | បរិមាណ | ទំនិញជាស្តុកសម្រាប់លក់ | | | | | | | ទំនិញមិនមែនជាស្តុកសម្រាប់លក់ ឬក្រៅពីទំនិញ | | យោង |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ថ្លៃលក់/ឯកតា (មុនគិតអាករ) | ថ្លៃដើម/ឯកតា (មុនគិតអាករ) | ថ្លៃលក់សរុប | អាករពិសេស | | មូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ | មូលដ្ឋានគិតអាករលើតម្លៃបន្ថែមនិងប្រាក់រំដោះពន្ធលើប្រាក់ចំណូល | ថ្លៃដើម/ឯកតា (រួមបញ្ចូលអាករ) | ថ្លៃសរុប | |
| | | | | | | មូលដ្ឋានគិតអាករ | ប្រាក់អាករ | | | | | |
| | | ១ | ២ | ៣ | ៤= ១ x ២ | ៥= ៤ x ៩០% | ៦= ៥ x អត្រា | ៧= ៤ + ៦ | ៨= ១ x ៣ | ៩ | ១០= ១ x ៩ | |
| ១ | ស្រាបៀរ ( ថែម ) | 4,000 | 10 | 5 | 40,000 | 36,000 | 10,800 | 50,800 | 20,000 | | | លេខវិក្កយបត្រ TI-001 |
| ២ | ស្រាបៀរ ( រង្វាន់ ) | 1,000 | 10 | 5 | 10,000 | 9,000 | 2,700 | 12,700 | 5,000 | | | លេខបណ្ណបញ្ចេញទំនិញ |
| ៣ | ទឹកក្រូច ( ថែម ) | 3,000 | 5 | 2 | 15,000 | 13,500 | 1,350 | - | 6,000 | | | លេខវិក្កយបត្រ TI-002 |
| ៤ | រថយន្ត ( រង្វាន់ ) | 1 | | | | | | | | 50,000 | 50,000 | លេខបណ្ណបញ្ចេញទំនិញ |
| ៥ | ម៉ូតូ ( រង្វាន់ ) | 5 | | | | | | | | 1,500 | 7,500 | លេខបណ្ណបញ្ចេញទំនិញ |
| ៦ | សាច់ប្រាក់ ( រង្វាន់ ) | 1 | | | | | | | | 20,000 | 20,000 | លេខបណ្ណផ្តល់រង្វាន់ |
| | | សរុប ( ដុល្លារអាមេរិក ) | | | 65,000 | 58,500 | 14,850 | 63,500 | 31,000 | | 77,500.00 | |
| | | សរុប ( រៀល ) | | | 266,500,000 | 239,850,000 | 60,885,000 | 260,350,000 | 127,100,000 | | 317,750,000 | |

**អត្រាប្តូរប្រាក់៖** ១ដុល្លារអាមេរិក = ៤ ១០០រៀល ( អត្រាប្តូរប្រាក់ប្រចាំថ្ងៃដែលចេញដោយធនាគារជាតិនៃកម្ពុជា )

**សម្គាល់៖**
- ត្រូវយកប្រអប់លេខ ៥ ជាមូលដ្ឋានគិតអាករពិសេសនៅក្នុង e-Filing
- ត្រូវយកប្រអប់លេខ ៧ ជាមូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈនៅក្នុង e-Filing
- ត្រូវយកប្រអប់លេខ ៨ ជាមូលដ្ឋានគណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលនៅក្នុង e-Filing
- ប្រអប់លេខ ១០ មិនមែនជាស្តុកទំនិញសម្រាប់លក់ និងមិនជាប់កាតព្វកិច្ចបង់ពន្ធអាករឡើយ។

ហត្ថលេខា និងឈ្មោះអ្នករៀបចំ

ហត្ថលេខា និងឈ្មោះអ្នកគ្រប់គ្រង

# ទម្រង់បណ្ណលក់ទី២

**ឈ្មោះក្រុមហ៊ុន** : ( **ជាភាសាខ្មែរ** )
Company Name : ( In English )
លេខអត្តសញ្ញាណកម្មសារពើពន្ធ (VATTIN) : □□□□-□□□□□□□□□
អាសយដ្ឋាន/Address :
ទូរស័ព្ទលេខ/Telephone :

## **បណ្ណលក់សម្រាប់ប្រកាសពន្ធ** ( Tax Sale Voucher )

សហគ្រាសនាំចូល ( ទំនិញជាប់អាករសម្រាប់បំភ្លឺសាធារណៈ )

**សម្រាប់ខែ.......... ឆ្នាំ២០២x**

លេខរៀងបណ្ណ :
Voucher No :
កាលបរិច្ឆេទ :
Date :

ការថែមទំនិញឬផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់ និងមិនមែនជាស្តុកសម្រាប់លក់ ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ

| ល.រ | ប្រភេទទំនិញថែម ឬផ្តល់ជារង្វាន់ | បរិមាណ | ទំនិញជាស្តុកសម្រាប់លក់ | | | | | ទំនិញមិនមែនក្នុងស្តុកសម្រាប់លក់ ឬក្រៅពីទំនិញ | | យោង |
|---|---|---|---|---|---|---|---|---|---|---|
| | | | ថ្លៃលក់/ឯកតា (មុនគិតអាករ) | ថ្លៃដើម/ឯកតា (មុនគិតអាករ) | ថ្លៃលក់សរុប | មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ | មូលដ្ឋានគិតអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល | ថ្លៃដើមទំនិញ/ឯកតា (រួមបញ្ចូលអាករ) | តម្លៃសរុប | |
| | | ១ | ២ | ៣ | ៤= ១ x ២ | ៥= ៤ | ៦= ១ x ៣ | ៧ | ៨= ១ x ៧ | |
| ១ | ស្រា ( ថែម ) | 300 | 250 | 150 | 75,000 | 75,000 | 45,000 | | | លេខវិក្កយបត្រ TI-001 |
| ២ | ស្ករ ( ថែម ) | 1,500 | - | 4 | - | - | 6,000 | | | លេខវិក្កយបត្រ TI-001 |
| ៣ | ឆត្រ ( ថែម ) | 1,500 | | | | | | 2 | 3,000 | លេខបណ្ណបញ្ចេញទំនិញ |
| | | | | | សរុប ( ដុល្លារអាមេរិក ) | 75,000 | 51,000 | | 3,000 | |
| | | | | | សរុប ( រៀល ) | 307,500,000 | 209,100,000 | | 12,300,000 | |

**អត្រាប្តូរប្រាក់៖** ១ដុល្លារអាមេរិក = ៤ ១០០រៀល ( អត្រាប្តូរប្រាក់ប្រចាំថ្ងៃដែលចេញដោយធនាគារជាតិនៃកម្ពុជា )

**សម្គាល់៖**
- ត្រូវយកប្រអប់លេខ ៥ ជាមូលដ្ឋានគិតសម្រាប់បំភ្លឺសាធារណៈនៅក្នុង e-Filing
- ត្រូវយកប្រអប់លេខ ៦ ជាមូលដ្ឋានគិតអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលនៅក្នុង e-Filing
- ប្រអប់លេខ ៨ មិនមែនជាស្តុកទំនិញសម្រាប់លក់ និងមិនជាប់កាតព្វកិច្ចបង់ពន្ធអាករឡើយ។

ហត្ថលេខា និងឈ្មោះអ្នករៀបចំ

ហត្ថលេខា និងឈ្មោះអ្នកគ្រប់គ្រង

# ទម្រង់បណ្ណលក់ទី៣

**ឈ្មោះក្រុមហ៊ុន** : (**ជាភាសាខ្មែរ**)
Company Name : (In English)
លេខអត្តសញ្ញាណកម្មសារពើពន្ធ (VATTIN) : ☐☐☐☐-☐☐☐☐☐☐☐☐☐
អាសយដ្ឋាន/Address :
ទូរស័ព្ទលេខ/Telephone :

**បណ្ណលក់សម្រាប់ប្រកាសពន្ធ** (Tax Sale Voucher)
សហគ្រាសផលិតឬនាំចូលឬផ្គត់ផ្គង់ទំនិញទូទៅ (មិនជាប់កាតព្វកិច្ចបង់អាករពិសេស និង/ឬអាករសម្រាប់បំភ្លឺសាធារណៈ)
**សម្រាប់ខែ.......... ឆ្នាំ២០២x**

លេខរៀងបណ្ណ :
Voucher No :
កាលបរិច្ឆេទ :
Date :

ការថែមទំនិញឬផ្តល់រង្វាន់នូវទំនិញជាស្តុកសម្រាប់លក់ និងមិនមែនជាស្តុកសម្រាប់លក់ ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ

| ល.រ | ប្រភេទមុខទំនិញថែម ឬផ្តល់ជារង្វាន់ | បរិមាណ | ទំនិញជាស្តុកសម្រាប់លក់ | | | ទំនិញមិនមែនជាស្តុកសម្រាប់លក់ ឬក្រៅពីទំនិញ | | យោង |
|---|---|---|---|---|---|---|---|---|
| | | | ថ្លៃទំនិញ/ឯកតា (មុនគិតអាករ) | ថ្លៃលក់សរុប | មូលដ្ឋានគិតអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូល | ថ្លៃដើម/ឯកតា (រួមបញ្ចូលអាករ) | តម្លៃសរុប | |
| | | ១ | ២ | ៣= ១ x ២ | ៤= ៣ | ៥ | ៦= ១ x ៥ | |
| ១ | កំសៀវអគ្គិសនី (ថែម) | 1,000 | 20 | 20,000 | 20,000 | | | លេខវិក្កយបត្រ TI-001 |
| ២ | អាវយឺត (ថែម) | 1,000 | | | | 5 | 5,000 | លេខវិក្កយបត្រ TI-001 |
| ៣ | ម៉ូតូ (ថែម) | 100 | | | | 1,500 | 150,000 | លេខបណ្ណបញ្ចេញទំនិញ |
| ៤ | បណ្ណសាំង (ថែម) | 50 | | | | 1,000 | 50,000 | លេខបណ្ណបញ្ចេញទំនិញ |
| ៥ | សំបុត្រដំណើរកម្សាន្ត (ថែម) | 50 | | | | 1,000 | 50,000 | លេខបណ្ណផ្តល់រង្វាន់ |
| | | **សរុប (ដុល្លារអាមេរិក)** | | 20,000 | 20,000 | | 255,000 | |
| | | **សរុប (រៀល)** | | 82,000,000 | 82,000,000 | | 1,045,500,000 | |

**អត្រាប្តូរប្រាក់:** ១ដុល្លារអាមេរិក = ៤ ១០០រៀល (អត្រាប្តូរប្រាក់ប្រចាំថ្ងៃដែលចេញដោយធនាគារជាតិនៃកម្ពុជា)
**សម្គាល់:** - ត្រូវយកប្រអប់លេខ ៤ ជាមូលដ្ឋានគណនាអាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលនៅក្នុង e-Filing
- ប្រអប់លេខ ៦ មិនមែនជាស្តុកទំនិញសម្រាប់លក់ និងមិនជាប់កាតព្វកិច្ចបង់ពន្ធអាករឡើយ។

ហត្ថលេខា និងឈ្មោះអ្នករៀបចំ

ហត្ថលេខា និងឈ្មោះអ្នកគ្រប់គ្រង